# ព្រះរាជាណាចក្រកម្ពុជា

## ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា

លេខ : ៩៧ អនក្រ.បក

## អនុក្រឹត្យ

## ស្តីពីការផ្ទេរឥណទានថវិកា

************

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យ នស/រកត/១១៩៨/៧២ , ចុះថ្ងៃទី ៣០ ខែ វិច្ឆិកា ឆ្នាំ ១៩៩៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា

  បានឃើញព្រះរាជក្រម ០២/នស/៩៤ , ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការរៀបចំ និង ការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រម នស/រកម/០១៩៦/១៨ , ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការបង្កើតក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ
- បានឃើញអនុក្រឹត្យលេខ ០៤ អនក្រ.បក , ចុះថ្ងៃទី ២០ ខែ មករា ឆ្នាំ ២០០០ ស្តីពីការរៀបចំ និង ការប្រព្រឹត្តទៅ នៃក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ
- បានឃើញព្រះរាជក្រម ០១/នស/៩៣ ,ចុះថ្ងៃទី ២៨ ខែ ធ្នូ ឆ្នាំ ១៩៩៣ ដែលប្រកាសអោយប្រើច្បាប់ស្តីអំពីប្រព័ន្ធហិរញ្ញវត្ថុ ហើយត្រូវបានកែប្រែដោយច្បាប់ស្តីពីហិរញ្ញវត្ថុ សំរាប់ការគ្រប់គ្រងឆ្នាំ ១៩៩៥ ដែលប្រកាសអោយប្រើដោយព្រះរាជក្រមលេខ ១១នស/៩៤ , ចុះថ្ងៃទី ៣១ ខែ ធ្នូ ឆ្នាំ ១៩៩៤ និង ត្រូវបានកែប្រែដោយច្បាប់ស្តីពីហិរញ្ញវត្ថុ សំរាប់ការគ្រប់គ្រងឆ្នាំ ២០០០ ដែលប្រកាសអោយប្រើដោយព្រះរាជក្រមលេខ នស/រកម/១២៩៩/១៥ , ចុះថ្ងៃទី ២៥ ខែ ធ្នូ ឆ្នាំ ១៩៩៩
- បានឃើញព្រះរាជក្រម នស/រកម/១២០០/១២ , ចុះថ្ងៃទី ៣០ ខែ ធ្នូ ឆ្នាំ ២០០០ ដែលប្រកាសអោយប្រើច្បាប់ស្តីពីហិរញ្ញវត្ថុ សំរាប់ការគ្រប់គ្រង ឆ្នាំ ២០០១
- បានឃើញអនុក្រឹត្យលេខ ០២ អនក្រ.បក , ចុះថ្ងៃទី ១០ ខែ មករា ឆ្នាំ ២០០១ ស្តីពីការបែងចែកឥណទានចំណាយថវិកាចំណាយ តាមជំពូកនៃច្បាប់ហិរញ្ញវត្ថុ សំរាប់ការគ្រប់គ្រង ឆ្នាំ ២០០១
- បានឃើញអនុក្រឹត្យលេខ ០៣ អនក្រ.បក , ចុះថ្ងៃទី ១០ ខែ មករា ឆ្នាំ ២០០១ ស្តីពីការផ្ទេរឥណទានថវិកា
- តាមសំណើរបស់ឯកឧត្តមទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ

## សំរេច

**មាត្រា១:** ត្រូវបានអនុញ្ញាតិអោយផ្ទេរឥណទានថវិកា ចំនួន ១.៥០០ លានរៀល ( មួយពាន់ប្រាំរយលានរៀលគត់ ) ពីជំពូក ៤០ ( ចំណាយផ្សេងៗ ) នៃខ្ទង់ចំណាយមិនទាន់បែងចែក មកជំពូក ១១ (ចំណាយដំណើរការរដ្ឋបាល សំភារៈ និង ការជួសជុលតូច ) របស់ទីស្តីការគណៈរដ្ឋមន្ត្រី សំរាប់ការគ្រប់គ្រងឆ្នាំ ២០០១ ។

**មាត្រា២:** ការបែងចែកឥណទានថវិកាចំណាយផ្ទៃក្នុងជំពូកទាំងនេះ តាមប្រការ កថាខ័ណ្ឌ និង វាក្យខ័ណ្ឌ ត្រូវធ្វើឡើងដោយប្រកាសរបស់រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ សំរាប់ចំណាយដំណើរការរដ្ឋបាលដែលខ្វះក្នុងឆ្នាំ ២០០១ ។

**មាត្រា៣:** រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ ត្រូវទទួលបន្ទុកអនុវត្តអនុក្រឹត្យនេះ ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

រាជធានីភ្នំពេញ , ថ្ងៃទី ២៦ ខែ កញ្ញា ឆ្នាំ ២០០១

នាយករដ្ឋមន្ត្រី

ហ៊ុន សែន

**ចំលងជូន**

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ដូចមាត្រា ៣
- កាលប្បវត្តិ - ឯកសារ

**បានយកសេចក្តីគោរពជូន**

**សម្តេចនាយករដ្ឋមន្ត្រី ដើម្បីចុះហត្ថលេខា**

**ទេសរដ្ឋមន្ត្រី**

**រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ**